# បុព្វកថា

*អត្ថបទទាំងឡាយ ដែលខ្ញុំបានសរសេរ និងចុសផ្សាយនៅពេលនេះ គឺសម្រាប់លោកអ្នក យកទៅពិចារណានូវធម្មព្រះពុទ្ធខ្លះ ដែលយើងធ្លាប់បានដឹង បានឮរួចមកហើយ។ តើលោកអ្នក បានយល់យ៉ាងណាដែរចំពោះធម៌ទាំងនោះ ?*

*ដោយខ្ញុំក៏ធ្លាប់បានឮ បានស្តាប់ នឹងបានពិចារណានូវធម៌ខ្លះនោះដែរ ខ្ញុំសូមជូននូវការយល់របស់ខ្ញុំ ដើម្បីនឹងពិចារណាតទៅទៀត ។ ដូចជាអ្នកអានរឿងជាតិជក ស្តីពីជីវិតព្រះពោធិសត្វ រឿងខ្លះយើងធ្លាប់ស្តាប់រួចមកហើយ តែយើងនៅតែចង់ស្តាប់ទៀត ដោយមកពីការបកស្រាយ សន្និដ្ឋាន រកគុណទោស ហេតុផល បុណ្យបាន មិនដូចគ្នាទាំងអស់ទេ ពីព្រោះការយល់មិនដូចគ្នា ។ យ៉ាងណាមិញ ធម៌ព្រះតែមួយ តែការពន្យល់ បកស្រាយ ក៏អាចមិនដូចគ្នាដែរ។ ត្រង់មិនដូចគ្នានេះហើយ ដែលជាកត្តាមួយសម្រាប់ឲ្យយើង យកមកពិចារណា ដោយប្រើបញ្ញា ពីព្រោះព្រះពុទ្ធក៏លោកឲ្យយើងជឿ (មានសទ្ធា) លើអ្វីមួយដោយប្រើបញ្ញាជាមុនដែរ ទុកជាធម៌របស់ព្រះអង្គ ក៏ព្រះអង្គឲ្យយើងប្រើបញ្ញាដែរ មុននឹងជឿ ។ លោកឲ្យយើងយកទៅធ្វើការពិសោធន៍សិន ដើម្បីមើលលទ្ធផល តើបានលទ្ធផលដូចបំណងយើងទេ ? បើមិនបានដូចបំណងទេ នោះព្រះអង្គក៏មិនបង្ខំ ឲ្យយើងធ្វើតាមព្រះអង្គដែរ ៕*